ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ១៩៩ ប្រក.កសក

# ប្រកាស
# ស្តីពី
# នីតិវិធីនិងសិទ្ធិពិន័យអន្តរការណ៍ លើបទល្មើសដែលមានចែង ក្នុងច្បាប់ស្តីពី ការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៥ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 211 351/211 352, Fax : (855) 23 - 217 320

- បានឃើញប្រកាសលេខ១៧៦ប្រក.កសក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៣ ស្ដីពីនីតិវិធីនៃការធ្វើអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម
- បានឃើញប្រកាសអន្តរក្រសួងលេខ៩៦កយ.កសក.ប្រក/១៣ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្ដីពីការផ្ដល់នីតិសម្បទាជានគរបាលយុត្តិធម៌
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

### ប្រការ ១.-

ប្រកាសនេះមានគោលបំណងកំណត់នូវនីតិវិធីនិងសិទ្ធិពិន័យអន្តរការណ៍ លើបទល្មើសដែលមានចែងក្នុងច្បាប់ស្ដីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

### ប្រការ ២.-

ប្រកាសនេះមានគោលដៅលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ ធ្វើឲ្យរាងចាលដល់ជនប្រព្រឹត្តបទល្មើស និងធ្វើការដោះស្រាយបទល្មើសដោយរំលត់បណ្ដឹងអាជ្ញា តាមរយៈការសារភាពកំហុសរបស់ជនល្មើស និងយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ដូចមានចែងក្នុងច្បាប់ស្ដីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

### ប្រការ ៣.-

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះការពិន័យអន្តរការណ៍លើបទល្មើស ដូចមានចែងក្នុងមាត្រា១០៦ មាត្រា១០៧ និងមាត្រា១០៨ នៃច្បាប់ស្ដីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

### ប្រការ ៤.-

ការពិន័យអន្តរការណ៍លើបទល្មើស ដែលមានចែងក្នុងច្បាប់ស្ដីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ត្រូវអនុវត្តដោយមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌ នៃនាយកដ្ឋាននីតិកម្មកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្មរាជធានី ខេត្ត។

### ប្រការ ៥.-

មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌ នៃនាយកដ្ឋាននីតិកម្មកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិអនុវត្តពិន័យអន្តរការណ៍ លើដែនដីជាតិទូទាំងព្រះរាជាណាចក្រកម្ពុជា។

មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌នៃមន្ទីរកសិកម្មរាជធានី ខេត្ត មានសិទ្ធិអនុវត្តពិន័យអន្តរការណ៍ នៅក្នុងដែនដីរាជធានី ខេត្តសាមី។

**ប្រការ ៦.-**

នាយកដ្ឋាននីតិកម្មកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិសម្រេចពិន័យអន្តរការណ៍លើគ្រប់បទល្មើស ដែលមានចែងក្នុងមាត្រា១០៦ មាត្រា១០៧ និងមាត្រា១០៨ នៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

**ប្រការ ៧.-**

មន្ទីរកសិកម្មរាជធានី ខេត្តមានសិទ្ធិសម្រេចពិន័យអន្តរការណ៍លើបទល្មើសដែលពាក់ព័ន្ធ ក្នុងចំណោមបទល្មើស ដែលមានចែងក្នុងមាត្រា១០៦ មាត្រា១០៧ និងមាត្រា១០៨ នៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ដូចខាងក្រោម៖

ក-មាត្រា ១០៦ ចំណុចទី១ ទី២ ទី៣ ទី៤ ទី៩ និងទី១០

ខ- មាត្រា ១០៧ ចំណុចទី១ ទី៥ ទី៧ ទី៨ ទី៩ និងទី១០

គ- មាត្រា ១០៨ ចំណុចទី៥ ទី៦ ទី៩ ទី១១ និងទី១២។

ក្នុងករណីការពិន័យអន្តរការណ៍ ត្រូវបានអនុវត្តលើបទល្មើសផ្សេងពីបទល្មើសដូចបានចែងក្នុងកថាខណ្ឌទី១ខាងលើ មន្ទីរកសិកម្មរាជធានី ខេត្ត ត្រូវបញ្ជូនរបាយការណ៍ ដោយភ្ជាប់ជាមួយនូវកំណត់ហេតុត្រួតពិនិត្យបទល្មើសនិងលិខិតសារភាពកំហុស មកនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីសម្រេចលើការបង់ប្រាក់ពិន័យអន្តរការណ៍តាមនីតិវិធី។

**ប្រការ ៨.-**

នៅពេលចុះបំពេញបេសកកម្មអនុវត្តច្បាប់ មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌ មានសមត្ថកិច្ចដឹកនាំបេសកកម្ម មានសិទ្ធិសម្រេចពិន័យអន្តរការណ៍ផ្ទាល់នៅនឹងកន្លែងកើតហេតុក្នុងករណីជនល្មើសសារភាពកំហុសនៅនឹងកន្លែងកើតហេតុ និងយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍លើបទល្មើស តាមច្បាប់ជាធរមាន។

រាល់ការពិន័យអន្តរការណ៍នៅនឹងកន្លែងកើតហេតុ មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌ មានសមត្ថកិច្ចដឹកនាំបេសកកម្ម ត្រូវចេញសេចក្តីសម្រេចពិន័យអន្តរការណ៍ឲ្យជនល្មើស ដើម្បីយកទៅបង់ប្រាក់ពិន័យអន្តរការណ៍នៅអង្គភាពមានសមត្ថកិច្ចសាមី ឬអាចទៅបង់ប្រាក់ពិន័យនៅរតនាគារជាតិ ឬនៅរតនាគាររាជធានី ខេត្តសាមីដោយផ្ទាល់ ក្នុងរយៈពេលមិនលើសពី១៥ (ដប់ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេចនៅនឹងកន្លែងកើតហេតុ។

**ប្រការ ៩.-**

ការសម្រេចពិន័យអន្តរការណ៍លើបទល្មើស ត្រូវផ្អែកតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- ការប្រព្រឹត្តល្មើសដោយចេតនា

- ការប្រព្រឹត្តល្មើសលើកដំបូង
- ការប្រព្រឹត្តល្មើសដោយមិនរាងចាល
- ទំហំនៃបទល្មើសឬតម្លៃវត្ថុតាងដែលជនល្មើសបានប្រព្រឹត្ត
- ទំហំខូចខាតនិងផលប៉ះពាល់ដល់មនុស្ស សត្វ និងបរិស្ថាន
- ផលប្រយោជន៍ចំពោះសង្គម សេដ្ឋកិច្ច និងបរិស្ថាន។

**ប្រការ ១០.-**

ការពិន័យអន្តរការណ៍អាចអនុវត្តបាន ក្នុងករណីជនល្មើសយល់ព្រមសារភាពកំហុសជាលាយលក្ខណ៍អក្សរជូនមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌ មានសមត្ថកិច្ចដឹកនាំបេសកកម្ម និងយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ស្របតាមទោសប្បញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

ក្នុងករណីជនល្មើសមិនព្រមសារភាពកំហុសនិងបង់ប្រាក់ពិន័យអន្តរការណ៍ មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌ មានសមត្ថកិច្ចដឹកនាំបេសកកម្ម មានសិទ្ធិចាត់វិធានការលើវត្ថុតាងឬលិខិតអនុញ្ញាតពាក់ព័ន្ធដែលត្រូវឃាត់ទុក ឬត្រូវដកហូតជាបណ្តោះអាសន្ននៅក្នុងប្រតិបត្តិការអធិការកិច្ច និងមានសិទ្ធិចាត់វិធានការបន្ត ដោយត្រូវចងក្រងសំណុំរឿងនៃបទល្មើសបញ្ជូនទៅតុលាការតាមនីតិវិធី។

**ប្រការ ១១.-**

ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃបានត្រួតពិនិត្យបទល្មើស និងបានចុះក្នុងកំណត់ហេតុត្រួតពិនិត្យ ជនប្រព្រឹត្តល្មើសអាចធ្វើលិខិតសារភាពកំហុសជូនមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ច នៅអង្គភាពមានសមត្ថកិច្ចពិន័យអន្តរការណ៍។

អង្គភាពមានសមត្ថកិច្ចពិន័យអន្តរការណ៍ ត្រូវចេញសេចក្តីសម្រេចពិន័យអន្តរការណ៍ក្នុងរយៈពេល០៧(ប្រាំពីរ)ថ្ងៃ គិតចាប់ពីថ្ងៃទទួលលិខិតសារភាពកំហុសរបស់ជនប្រព្រឹត្តល្មើស។

ជនប្រព្រឹត្តល្មើសត្រូវបង់ប្រាក់ពិន័យអន្តរការណ៍ នៅអង្គភាពមានសមត្ថកិច្ចពិន័យអន្តរការណ៍សាមី ឬអាចបង់ប្រាក់ពិន័យអន្តរការណ៍នៅរតនាគារជាតិ ឬនៅរតនាគាររាជធានី ខេត្តសាមី នូវបរិមាណទឹកប្រាក់ដូចបានកំណត់ក្នុងសេចក្តីសម្រេចពិន័យអន្តរការណ៍ នៅក្នុងរយៈពេលមិនលើសពី១៥(ដប់ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេច។

គំរូទម្រង់លិខិតសារភាពកំហុស និងសេចក្តីសម្រេចស្តីពីការពិន័យអន្តរការណ៍ ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ១២.-**

ក្រោយពេលបង់ប្រាក់ពិន័យអន្តរការណ៍គ្រប់ចំនួនរួច សាមីជនត្រូវរួចផុតពីការចោទប្រកាន់ទៅតុលាការ វត្ថុតាងនៃបទល្មើសត្រូវប្រគល់ជូនសាមីជនវិញ លើកលែងតែវត្ថុតាងជាថ្នាំ

កសិកម្មឬជីកសិកម្មណា ដែលជាផលិតផលមានគ្រោះថ្នាក់ ជាផលិតផលឬសារធាតុហាមឃាត់ ដោយច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម។

សាមីជនត្រូវទទួលបន្ទុកចំណាយក្នុងការលើកដាក់ ដឹកជញ្ជូន និងថែរក្សាវត្ថុតាង នៅក្នុងដំណើរការដោះស្រាយបទល្មើស។

**ប្រការ ១៣.-**

ក្នុងករណីជនប្រព្រឹត្តល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍តាមបរិមាណទឹកប្រាក់កំណត់ ឬផុតកាលបរិច្ឆេទកំណត់ដូចមានចែងក្នុងសេចក្តីសម្រេចពិន័យអន្តរការណ៍ អង្គភាពមានសមត្ថកិច្ចសាមី ត្រូវបញ្ជូនសំណុំរឿងទៅតុលាការតាមនីតិវិធី។

**ប្រការ ១៤.-**

អង្គភាពមានសមត្ថកិច្ចសាមី ត្រូវបង់ប្រាក់ចំណូលដែលបានមកពីការពិន័យអន្តរការណ៍ចូលថវិកាជាតិតាមរយៈរតនាគារជាតិឬរតនាគាររាជធានី ខេត្តសាមី ស្របតាមនីតិវិធី។

មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌មានសមត្ថកិច្ច ត្រូវធ្វើរបាយការណ៍ជាប្រចាំជូនអង្គភាពមានសមត្ថកិច្ចសាមី និងជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អំពីរាល់ករណីពិន័យអន្តរការណ៍ដែលបានអនុវត្ត។

**ប្រការ ១៥.-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រធានមន្ទីរកសិកម្មរាជធានីខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងខ្លួនៗ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ១៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# លិខិតសារភាពកំហុស និង
# យល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍

ខ្ញុំឈ្មោះ.......................................ភេទ..........អាយុ.......... ឆ្នាំ សញ្ជាតិ......................
អាសយដ្ឋានបច្ចុប្បន្ន៖ ..............................................................................................
......................................................................................................................
មុខរបរ៖.........................................................................................................
☐ កាន់អត្តសញ្ញាណប័ណ្ណលេខ..............................ផុតកំណត់៖...................................
☐ លិខិតឆ្លងដែនលេខ.........................................ផុតកំណត់៖...................................

## សូមគោរពជូន

........................................................................................ (១)

**កម្មវត្ថុ** ៖ សេចក្តីសារភាពកំហុសនិងស្នើសុំបង់ប្រាក់ពិន័យអន្តរការណ៍។

**យោង** ៖ កំណត់ហេតុត្រួតពិនិត្យ ចុះថ្ងៃទី.........ខែ................ឆ្នាំ២០១.......។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូន(១) ...............
...................................................មេត្តាជ្រាបថា៖ កាលពីថ្ងៃទី........ខែ............ឆ្នាំ២០១......
វេលាម៉ោង.......................ខ្ញុំបានប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ដូចបានចុះក្នុងកំណត់ហេតុត្រួតពិនិត្យរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ច ដូចខាងក្រោម៖

......................................................................................................................
......................................................................................................................
......................................................................................................................
......................................................................................................................
......................................................................................................................
......................................................................................................................
......................................................................................................................

(១) លោកប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ឬប្រធានមន្ទីរកសិកម្មរាជធានី ខេត្ត ឬមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌ដឹកនាំបេសកកម្ម

ខ្ញុំសូមសារភាពកំហុសនិងយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍ចំនួន...............................
(សរសេរជាអក្សរៈ......................................................................................................)
ស្របតាមសេចក្តីសម្រេចពិន័យអន្តរការណ៍ ដើម្បីរំលត់បណ្តឹងអាជ្ញា និងរួចផុតពីការចោទប្រកាន់ទៅតុលាការ។

ខ្ញុំសូមសន្យាថានឹងឈប់ប្រព្រឹត្តអំពើល្មើសច្បាប់ដូចខាងលើចាប់ពីពេលនេះតទៅ ខ្ញុំសូមផ្តិតស្នាមម្រាមដៃទុកជាភស្តុតាងចំពោះមុខច្បាប់។

អាស្រ័យហេតុនេះ សូមលោក(១)..................................................................................
មេត្តាពិនិត្យ និងសម្រេចដោយអនុគ្រោះ។

........................ថ្ងៃទី..........ខែ................ឆ្នាំ ២០១.....

**ស្នាមម្រាមដៃអ្នកសារភាពកំហុស**

---

(១) ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ឬប្រធានមន្ទីរកសិកម្មរាជធានី ខេត្ត
ឬមន្ត្រីអធិការកិច្ចថ្នាក់កសិកម្មនិងជីកសិកម្មដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌ដែលដឹកនាំបេសកកម្ម

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

(១)..............................................................................

លេខ____________________ពអ/________

# សេចក្តីសម្រេច
# ស្តីពីការពិន័យអន្តរការណ៍

...........................................................................................(២)

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៥ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម
- បានឃើញប្រកាសលេខ១៧៦ប្រក.កសក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការធ្វើអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម
- បានឃើញប្រកាសលេខ...............ប្រក.កសក ចុះថ្ងៃទី...........ខែ................ឆ្នាំ២០១.... ស្តីពីនីតិវិធីនិងសិទ្ធិពិន័យអន្តរការណ៍លើបទល្មើសនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម
- បានឃើញប្រកាសអន្តរក្រសួងលេខ៩៦កយ.កសក.ប្រក/១៣ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌
- បានឃើញកំណត់ហេតុត្រួតពិនិត្យ ចុះថ្ងៃទី.........ខែ...........ឆ្នាំ២០១.... របស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ច
- យោងតាមលិខិតសារភាពកំហុស និងយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍ របស់ជនប្រព្រឹត្តល្មើស ចុះថ្ងៃទី......... ខែ.................. ឆ្នាំ២០១.....

## សម្រេច

**១-** ធ្វើការពិន័យអន្តរការណ៍ជាប្រាក់ចំនួន៖............................................................
(សរសេរជាអក្សរ៖.........................................................................................)
ចំពោះឈ្មោះ..................................... ភេទ............ អាយុ..........ឆ្នាំ សញ្ជាតិ....................
ដែលបានប្រព្រឹត្តិល្មើសនឹងច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ដូចខាងក្រោម៖

---

(១) នាយកដ្ឋាននីតិកម្មកសិកម្ម ឬមន្ទីរកសិកម្មរាជធានី ខេត្ត

(២) ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ឬប្រធានមន្ទីរកសិកម្មរាជធានី ខេត្ត
ឬមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌ដែលដឹកនាំបេសកកម្ម

មាត្រា........ ចំណុចទី...........ពីបទះ..............................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................។

**២**- ជនប្រព្រឹត្តិល្មើសត្រូវបង់ប្រាក់ពិន័យអន្តរការណ៍ នៅនាយកដ្ឋាននីតិកម្មកសិកម្ម ឬនៅមន្ទីរកសិកម្មរាជធានី ខេត្តសាមី ឬអាចបង់ប្រាក់ពិន័យអន្តរការណ៍ដោយផ្ទាល់ នៅធនាគារជាតិ ឬនៅធនាគាររាជធានី ខេត្តសាមី នៅក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃចេញសេចក្ដីសម្រេចនេះ។

ក្នុងករណីបង់ប្រាក់ពិន័យនៅធនាគារ សាមីជនត្រូវយកសក្ខីបត្រទទួលប្រាក់ដែលចេញដោយធនាគារ មកបង្ហាញជូននាយកដ្ឋាននីតិកម្មកសិកម្ម ឬនៅមន្ទីរកសិកម្មរាជធានី ខេត្ត ជាអង្គភាពមានសមត្ថកិច្ចសាមី ដើម្បីបញ្ចប់សំណុំរឿងករណីបទល្មើស។

**៣**- ក្នុងករណីសាមីជនមិនបានបង់ប្រាក់ពិន័យអន្តរការណ៍គ្រប់ចំនួន នៅមុនថ្ងៃទី..................ខែ....................ឆ្នាំ...................ទេ អង្គភាពមានសមត្ថកិច្ចសាមី នឹងចងក្រងសំណុំរឿងនៃបទល្មើសដើម្បីបញ្ជូនទៅតុលាការតាមនីតិវិធី។

**៤**-សាមីជនដែលសារភាពកំហុស និងយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ត្រូវទទួលខុសត្រូវអនុវត្តសេចក្ដីសម្រេចនេះ ចំពោះមុខច្បាប់។

..............................,ថ្ងៃទី.............ខែ............... ឆ្នាំ២០.....

..........................................................................(១)

**ចម្លងជូនៈ**

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- នាយកដ្ឋាននីតិកម្មកសិកម្ម
  "ដើម្បីជូនជ្រាប"
- ដូចចំណុចទី៤
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

---

(១) ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ឬប្រធានមន្ទីរកសិកម្មរាជធានី ខេត្ត
ឬមន្ត្រីអធិការកិច្ចថ្នាក់កសិកម្មនិងជំកសិកម្មដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌ដែលដឹកនាំបេសកកម្ម